# ត្រៃសរណគមន៍

**ពុទ្ធំ សរណំ គច្ឆាមិ** *ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធ ជាទីពឹងទីរឭក ។*

**ធម្មំ សរណំ គច្ឆាមិ** *ខ្ញុំព្រះករុណាសូមដល់នូវព្រះធម៌ ជាទីពឹងទីរឭក ។*

**សង្ឃំ សរណំ គច្ឆាមិ** *ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃ ជាទីពឹងទីរឭក ។*

**ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** *ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក (ជាគម្រប់ពីរដង) ។*

**ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ** *ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរឭក (ជាគម្រប់ពីរដង) ។*

**ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** *ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក (ជាគម្រប់ពីរដង) ។*

**តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** *ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក (ជាគម្រប់បីដង) ។*

**តតិយម្បិ ធម្មំ សរណំ គច្ឆាមិ** *ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរឭក (ជាគម្របីដង) ។*

**តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** *ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក (ជាគម្រប់បីដង) ។*

# សិក្ខាបទ ៥

**១. បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ**

*ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វ មានជីវិតឲ្យធ្លាក់ចុះ គឺសម្លាប់សត្វ ។*

**២. អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ**

*ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យដោយកាយ ឬដោយវាចា ។*

**៣. កាមេសុមិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ**

*ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។*

**៤. មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ**

*ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយានិយាយនូវពាក្យកុហក ។*

**៥. សុរាមេរយមជ្ជបមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ**

*ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ។*

# ធម៌សុំសេចក្តីសុខ សេចក្តីចម្រើន

**ឥច្ចេវមច្ចន្ត នមស្សនេយ្យំ នមស្សមានោ រតនត្តយំ យំ**

**បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ តស្សានុភាវេន ហតន្តរាយោ ។**

*ខ្ញុំសូមនមស្សការ លើកហត្ថាឱនសិរសី បង្គំគុណទាំងបី ខ្ពស់លើសលប់ត្រៃលោកា សូមបុណ្យកងកុសល ឲ្យមានដល់យើងខ្ញុំណា ពេញពោរស្មើធារា ដូចជលសាធំទូលាយ សូមឲ្យកំចាត់បង់ អពមង្គលទាំងឡាយ ឲ្យជៀសចេញចាកឆ្ងាយ ក្តីអន្តរាយកុំបីមាន ដោយកម្លាំងអានុភាព បុញ្ញលាភជាប្រធាន កងបុណ្យរាសីមាន សូមបានក្សាន្តកុំមានមោះ ដោយគុណនមស្សការ ត្រៃរតនាប្រសើរខ្ពស់ សូមអានិសង្សនោះ ដាក់ដល់ឋាននិព្វានហោង៕*



# ធម្មសង្វេគបច្ចវេក្ខណបាដ្ឋក

សព្វេ សង្ខារា អនិច្ចា សព្វេ សង្ខារា ទុក្ខា សព្វេ ធម្មា អនត្តា ។ អធុវំ ជីវិតំ ធុវំ មរណំ អវស្សំ មយា មរិតព្វំ មរណបរិយោសានំ មេ ជីវិតំ ។ ជីវិតំ មេ អនិយតំ មរណំ មេ និយតំ ។ អចិរំ វត អយំ កាយោ បឋវឹ អធិសេស្សតិ ឆុឌ្ឌោ អបេតវិញ្ញាណោ និរត្ថំ វកលីគរំ ។

សព្វេ សង្ខារា អនិច្ចា    សង្ខារគឺរាងកាយ និងចិត្ត
ព្រមទាំងរូបធម៌នាមធម៌ពិត    ទាំងអស់នេះឥតទៀងទាត់ទេ ។
ព្រោះកើតឡើងហើយត្រូវរលត់    មានហើយក៏ផុតទាំងយើងគេ
មនុស្សសត្វទេវតាមិនទំនេរ    ក្មេងចាស់ផងដែរគួរអាណិត ។
សព្វេ សង្ខារា ទុក្ខា    សង្ខារគឺរាងកាយ និងចិត្ត
ព្រមទាំងរូបធម៌នាមធម៌ពិត    ទាំងអស់នេះឥតបានសុខឡើយ។
កើតចាស់ឈឺស្លាប់គ្រប់ៗ គ្នា    គ្រប់ពេលវេលាពុំដែលស្បើយ
គេចមិនរួចទេកាលកើតហើយ    គេចមិនរួចឡើយពីរឿងនេះ ។
សព្វេ ធម្មា អនត្តា    វត្ថុផងណាគង់វបេះ
គង់បានទទួលផលដូច្នេះ    ព្រោះតែធម៌នេះមិនមែនខ្លួន ។
អធុវំ ជីវិតំ ធម៌    ជីវិតនេះហ្ន៎មិនខ្ជាប់ខ្ជួន

*ប្រែប្រួលជានិច្ចទៅតាមក្បួន* *ថាជីវិតខ្លួនមិនស្ថិតស្ថេរ ។*
**ធុវំ មរណំ** *ធម៌នេះពិត* *ថាយើងឥតនៅបានយូរទេ*
*ព្រោះតែធម៌នេះមិនស្ថិតស្ថេរ* *ទើបនាំយើងគេឲ្យស្លាប់ពិត ។*
**អវស្សំ មយា មរិតព្វំ** *មច្ចុជើងខ្លាំងមិនដែលអាណិត*
*អាសូទេវតាឬមួយសត្វ* *មច្ចុតាមកាត់ជីវិតគ្រប់គ្នា ។*
**មរណបរិយោសានំ** *គ្មានគ្រឿងប្រឆាំងរាំងការពារ*
**មេ ជីវិតំ** *យើងរាល់គ្នា* *ចាស់ក្មេងឈឺជាស្លាប់ប្រាកដ ។*
**ជីវិតំ មេ អនិយតំ** *ព្រោះជីវិតយើងមិនទៀងទាត់*
**មរណំ មេ និយតំ** *(ទីបំផុត)* *ជីវិតប្រាកដស្លាប់ទាត់ទៀង ។*
**អចិរំ វត អយំ កាយោ** *កាយនេះហ្ន៎សង្វេគឥតល្មៀង*
*កាលបើវិញ្ញាណប្រាសចាករាង* *នឹងដេកដួលគ្រាងលើផែនដី ។*
*រាងកាយអ្នកមានឬអ្នកក្រ* *ផាត់ស្គមខ្មៅស ប្រុសឬស្រី*
*កាលបើស្លាប់ហើយគ្មានន័យអ្វី* *គេមិនគប្បីទុកលើផ្ទះ ។*
*គេនាំទៅកប់ឬបូជា* *នៅលើទីឆ្លាណាមិនច្បាស់*
*ជូននៅក្នុងវត្ត ជូនកៀនផ្ទះ* *ជូនក្នុងព្រៃក្រាស់ឆ្ងាយកន្លង ។*
*រួចហើយគេនាំគ្នាវិលវិញ* *យើងនៅទោម្នេញក្នុងព្រៃស្រោង*
*ព្រៃដែលគេស្គាល់ព្រៃខ្មោចលង* *ព្រៃនោះឯងហោងជាផ្ទះថ្មីអ្នក ៕*